ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

រវាង

## មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

និង

## អង្គការសុខភាពគ្រួសារអន្តរជាតិ ប្រចាំប្រទេសកម្ពុជា

សម្រាប់ការអនុវត្តន៍សកម្មភាពបង្ការ និងថែទាំព្យាបាល

ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

នៅប្រទេសកម្ពុជា

ខែកញ្ញា ឆ្នាំ២០០៨ ដល់ ខែកញ្ញា ឆ្នាំ២០០៩

fhi Family Health International

អង្គការសុខភាពគ្រួសារអន្តរជាតិ

## ១ សេចក្តីផ្តើម

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល ព្រះរាជាណាចក្រកម្ពុជា និងអង្គការសុខភាពគ្រួសារអន្តរជាតិប្រចាំប្រទេសកម្ពុជា បានឯកភាពចំពោះកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលដ៏ជិតស្និទ្ធរវាងស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីពង្រឹងការលើកកំពស់ និងផ្តល់សេវាថែទាំសុខភាព ជាពិសេសការបង្ការ និងថែទាំអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ និងជំងឺកាមរោគ។

នៅឆ្នាំ ២០០៩ អង្គការសុខភាពគ្រួសារអន្តរជាតិប្រចាំកម្ពុជា នឹងធ្វើការសហប្រតិបត្តិការជាដៃគូ ជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដើម្បីធ្វើអោយមានភាពប្រសើរឡើង នូវសេវាថែទាំព្យាបាលជំងឺកាមរោគសំរាប់ស្ត្រីបំរើសេវាកំសាន្តសប្បាយ និងបុរសស្រឡាញ់បុរស, ក្រុមអប់រំផ្ទាល់/មិត្តអប់រំមិត្ត និងគាំទ្រដល់គោលនយោបាយប្រើប្រាស់ស្រោមអនាម័យ១០០% របស់រាជរដ្ឋាភិបាល នៅក្នុងខេត្តទាំងប្រាំបួនដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។

នៅថ្នាក់ខេត្ត គណៈកម្មាធិការប្រើប្រាស់ស្រោមអនាម័យខេត្ត, ក្រុមអប់រំផ្ទាល់/មិត្តអប់រំមិត្ត, មន្ត្រីគ្លីនិកសុខភាពគ្រួសារ (គ្លីនិកព្យាបាលជំងឺកាមរោគ), អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលគាំទ្រដោយអង្គការសុខភាពគ្រួសារអន្តរជាតិប្រចាំកម្ពុជា និងស្ថាប័នពាក់ពន្ធ័មួយចំនួនផ្សេងទៀត នឹងធ្វើការសំរបសំរួល និងសហការយ៉ាងជិតស្និទ្ធិជាមួយគ្នា ដើម្បីផ្តល់សេវាថែទាំព្យាបាលជំងឺកាមរោគ ព្រមទាំងការអប់រំសុខភាពអំពីមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ ដល់ក្រុមគោលដៅដែលប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់ ។

អង្គការសុខភាពគ្រួសារអន្តរជាតិប្រចាំប្រទេសកម្ពុជា នឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការផ្គត់ផ្គង់ដល់សេវាថែទាំព្យាបាលជំងឺកាមរោគសំរាប់ស្ត្រីបំរើការកំសាន្តសប្បាយ និងក្រុមបុរសស្រឡាញ់បុរស។ ម្យ៉ាងវិញទៀត ការឆ្លើយតបរួមគ្នារវាងគ្លីនិកសុខភាពគ្រួសារ និងសេវាថែទាំបន្តចំពោះអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ត្រូវបានអនុវត្តនៅខេត្តកំពង់ចាម, ខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

## ២ គោលបំណងសំខាន់នៃកិច្ចព្រមព្រៀង

គឺដើម្បីធ្វើអោយគុណភាពនៃសេវាថែទាំព្យាបាលជំងឺកាមរោគ នៅគ្លីនិកសុខភាពគ្រួសារ (គ្លីនិកព្យាបាលកាមរោគ) សំរាប់ស្ត្រីបំរើការកំសាន្តសប្បាយ និងក្រុមបុរសស្រឡាញ់បុរស មានភាពប្រសើរឡើង។

## ៣ គោលដៅជាក់លាក់នៃកិច្ចព្រមព្រៀង

៣.១ ដើម្បីបង្កើននូវភាពងាយស្រួលដល់ ស្ត្រីបំរើសេវាកំសាន្តសប្បាយ (នៅតាមផ្ទះបន ឬក្រៅផ្ទះបន) និងក្រុមប្រឈមមុខខ្ពស់ផ្សេងៗទៀតដូចជា ក្រុមបុរសស្រឡាញ់បុរស អោយមកទទួលសេវាថែទាំ និងព្យាបាលជំងឺកាមរោគ នៅគ្លីនិកសុខភាពគ្រួសារ ។

៣.២ ដើម្បីលើកកំពស់ និងពង្រឹងការប្រើប្រាស់តេស្តមន្ទីពិសោធន៍ សំរាប់ធ្វើរោគវិនិច្ឆ័យជំងឺកាមរោគនៅគ្រប់ គ្លីនិកសុខភាពគ្រួសារ ជាពិសេសចំពោះក្រុមដែលប្រឈមមុខខ្ពស់ ។

៣.៣ ដើម្បីលើកកំពស់ទំនាក់ទំនងអោយបានជិតស្និទ្ធរវាង គ្លីនិកសុខភាពគ្រួសារ កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០% និងក្រុមអប់រំផ្ទាល់/មិត្តអប់រំមិត្ត នៅក្នុងតំបន់គោលដៅ ។

៣.៤ ដើម្បីកសាង និងពង្រឹងសមត្ថភាពជូនដល់អ្នកផ្តល់សេវា ដែលកំពុងបំរើការនៅគ្លីនិកសុខភាពគ្រួសារ (គ្រូពេទ្យ និងអ្នកបច្ចេកទេសមន្ទីរពិសោធន៍) អោយផ្តល់សេវាថែទាំព្យាបាលដែលមានគុណភាពខ្ពស់ រួមទាំងការអប់រំផ្តល់ប្រឹក្សាដល់ក្រុមដែលប្រឈមមុខខ្ពស់ តាមរយៈការបណ្តុះបណ្តាលជាមូលដ្ឋានគ្រឹះ និងការបណ្តុះបណ្តាលបន្តនៅនឹងកន្លែងផ្តល់សេវា ។

៣.៥ ដើម្បីសំរបសំរួល និងសហការជាមួយដៃគូផ្សេងទៀត (សេវាសុខភាពសាធារណៈ គ្លីនិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ) ក្នុងការពង្រឹងប្រពន្ធ័សេវាបញ្ជូន ជាពិសេសការធ្វើតេស្តរកមេរោគអេដស៍ក្នុងចំណោមអ្នកជំងឺកាមរោគ, ការធ្វើតេស្តរកជំងឺកាមរោគក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេសដឺ និងការបញ្ជូនទៅវិញទៅមកជាមួយសេវាសុខភាពបន្តពូជ ។

៣.៦ ដើម្បីកំណត់នូវសកម្មភាពថ្មីៗមួយចំនួនដែលមិនទាន់មាននៅក្នុងកម្មវិធីនៅឡើយ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតំរូវការរបស់ក្រុមប្រឈមមុខខ្ពស់នូវសេវាថែទាំព្យាបាលជំងឺកាមរោគ ។

៣.៧ ដើម្បីពង្រឹងរបាយការណ៍ស្តីពីករណីជំងឺកាមរោគ ការគ្រប់គ្រងទិន្នន័យ និងប្រព័ន្ធរបាយការណ៍ ក្នុងគោលបំណងប្រើប្រាស់ទិន្នន័យទាំងនោះ សំរាប់ធ្វើអោយគុណភាពនៃសេវាថែទាំព្យាបាលជំងឺកាមរោគ និងការរៀបចំផែនការសកម្មភាពកាន់តែប្រសើរឡើង ។

## ៤ ទីកន្លែងផ្តល់សេវា និងផ្នែកសំខាន់ៗនៃការគាំទ្រ

អង្គការសុខភាពគ្រួសារអន្តរជាតិប្រចាំប្រទេសកម្ពុជា នឹងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយមន្ទីរសុខាភិបាលខេត្ត និងកម្មវិធីប្រយុទ្ធនឹងជំងឺអេសដឺនិងកាមរោគខេត្ត ដើម្បីពង្រឹងសេវាថែទាំព្យាបាលជំងឺកាមរោគនៅគ្លីនិកសុខភាពគ្រួសារទាំង ១៣ ក្នុងខេត្ត ចំនួន ៩ ដោយមានកិច្ចសហការពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។ គ្លីនិកសុខភាពគ្រួសារទាំងនោះ មានរាយឈ្មោះដូចខាងក្រោមនេះ :

១- ខេត្តកំពង់ចាម : គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តកំពង់ចាម, ទីរួមស្រុកត្បូងឃ្មុំ និងមេមត់

២- ខេត្តពោធិ៍សាត់: គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តពោធិ៍សាត់

៣- ខេត្តបាត់ដំបង: គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តបាត់ដំបង និងទីរួមស្រុកសំពៅលូន

៤- ខេត្តប៉ៃលិន: គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តប៉ៃលិន

៥- ខេត្តសៀមរាប: គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តសៀមរាប

៦- ខេត្តបន្ទាយមានជ័យ: គ្លីនិកសុខភាពគ្រួសារ សេរីសោភ័ណ និងប៉ោយប៉ែត

៧- ខេត្តព្រះសីហនុ: គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តព្រះសីហនុ

៨- ខេត្តកោះកុង: គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តកោះកុង

៩- ខេត្តកំពង់ឆ្នាំង: គ្លីនិកសុខភាពគ្រួសារ ទីរួមខេត្តកំពង់ឆ្នាំង

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មន្ទីរសុខាភិបាលខេត្ត និងអង្គការសុខភាពគ្រួសារអន្តរជាតិប្រចាំប្រទេសកម្ពុជា នឹងរួមសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីពង្រឹងយន្តការបញ្ជូនអតិថិជនរវាង គ្លីនិកសុខភាពគ្រួសារ និងសេវាថែទាំព្យាបាលបន្តអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ នៅខេត្តបាត់ដំបង, ខេត្តកំពង់ចាម និងខេត្តប៉ៃលិន ។ បទពិសោធន៍នៃការអនុវត្តន៍សកម្មភាពនេះនឹងត្រូវបានកត់ត្រាចងក្រងជាឯកសារយ៉ាងជាក់លាក់អំពីដំណើរការនៃការអនុវត្តន៍, ឧបស័គ្គនានា និងសមិទ្ធផលរបស់ការងារនេះ សំរាប់ជាគំរូដល់គ្លីនិកសុខភាពគ្រួសារដទៃទៀត ដែលត្រូវជ្រើសរើសបន្តនៅពេលអនាគត ។

## ៥ ភារៈកិច្ចទទួលខុសត្រូវរបស់ភាគីនិមួយៗ

ភាគីនិមួយៗមានតួនាទី និងភារៈកិច្ចទទួលខុសត្រូវដូចខាងក្រោម :

### ៥.១ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

៥.១.១ សហការ និងសំរបសំរួល ក្នុងការពិនិត្យឡើងវិញនូវគុណភាពសេវារបស់គ្លីនិកសុខភាពគ្រួសារ ដើម្បីរៀបចំជារបាយការណ៍សង្ខេបស្តីពីបញ្ហា និងការខ្វះខាតនានារបស់គ្លីនិកសុខភាពគ្រួសារ ព្រមទាំងការផ្តល់ជាអនុសាសន៍ជាក់ស្តែងដែលអាចអនុវត្តបាន សំរាប់ធ្វើអោយសេវាថែទាំព្យាបាលមានគុណភាពកាន់តែល្អប្រសើរឡើង ។

៥.១.២ ពិនិត្យ និងកែសំរួលឡើងវិញនូវយុទ្ធសាស្រ្តគ្រប់គ្រងព្យាបាលជំងឺកាមរោគ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យគុណភាពរបស់គ្លីនិកសុខភាពគ្រួសារ ដើម្បីផ្តល់ភាពងាយស្រួលដល់ស្ត្រីបំរើសេវាកំសាន្តសប្បាយ និងក្រុមបុរសស្រឡាញ់បុរស ដែលមកទទួលសេវានៅគ្លីនិកទាំងនោះ។

៥.១.៣ រៀបចំការបណ្តុះបណ្តាលជាមូលដ្ឋានគ្រឹះ ជូនដល់មន្ត្រីគ្លីនិកសុខភាពគ្រួសារ ស្តីពីការគ្រប់គ្រងព្យាបាលជំងឺកាមរោគដោយពឹងផ្អែកលើតេស្តមន្ទីរពិសោធន៍ រួមទាំងការអប់រំផ្តល់ប្រឹក្សាដល់អតិថិជនដែលមកទទួលសេវានៅគ្លីនិកទាំងនោះផង។

៥.១.៤ ផ្តល់ឱសថ និងប្រតិករដែលស្នើសុំ ជូនដល់គ្លីនិកសុខភាពគ្រួសារ (គ្លីនិកព្យាបាលជំងឺកាមរោគ) តាមរយៈឃ្លាំងឱសថកណ្តាល (CMS), មន្ទីរសុខាភិបាលខេត្ត និងឃ្លាំងឱសថស្រុកប្រតិបត្តិ។

៥.១.៥ សំរួល និងដោះស្រាយបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំសំរបសំរួលជាមួយភាគីដៃគូពាក់ព័ន្ធ (ដូចជាកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%, ក្រុមអប់រំផ្ទាល់/មិត្តអប់រំមិត្ត,..)

៥.១.៦ ផ្តល់ថវិកាឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រីដែលកំពុងបំរើការនៅគ្លីនិកសុខភាពគ្រួសារ។

៥.១.៧ ផ្តល់ការគាំទ្រដល់ការគ្រប់គ្រងសំភារៈ និងបរិក្ខារនៅគ្លីនិកសុខភាពគ្រួសារ។

៥.១.៨ ត្រួតពិនិត្យ និងគ្រប់គ្រងទិន្នន័យ និងប្រពន្ធ័រាយការណ៍របស់គ្លីនិកសុខភាពគ្រួសារ ដើម្បីធានាបាននូវការប្រមូលពតិមាន និងរបាយការណ៍អោយបានគ្រប់គ្រាន់ និងមានសុក្រិតភាព។

៥.១.៩ សហការជាមួយអង្គការពាក់ព័ន្ធ ដើម្បីពង្រឹងសេវាតាមរយៈការបង្កើនសមត្ថភាព ការធ្វើអោយកាន់តែប្រសើរនូវគុណភាព និងការធានាគុណភាព សំរាប់ការធ្វើតេស្តរកជំងឺកាមរោគ ហើយត្រូវមានទំនាក់ទំនងជាមួយសេវាផ្សេងៗទៀត ដូចជាសេវាធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ សេវាពន្យារកំនើត សេវាសុខភាពបន្តពូជ និងសេវាថៃទាំព្យាបាលបន្ត និងការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍។

៥.១.១០ ចែករំលែកពតិមានស្តីពីគំរោងផែនការប្រចាំឆ្នាំសំរាប់ការបង្ការ និងថៃទាំព្យាបាលជំងឺកាមរោគដល់ក្រុមគោលដៅជាក់លាក់ និងប្រភពថវិកាដែលទទួលបាន។ ចែករំលែករបាយការណ៍ស្តីពីករណីជំងឺកាមរោគ និងរបាយការណ៍នៃការចុះពិនិត្យតាមដាន និងអភិបាលសេវាថៃទាំព្យាបាល នៅគ្លីនិកសុខភាពគ្រួសារដែលបានចុះកិច្ចព្រមព្រៀងជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ។

### ៥.២ ការទទួលខុសត្រូវរបស់មន្ទីរសុខាភិបាលខេត្ត/កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍និងកាមរោគខេត្ត

៥.២.១ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់មន្ត្រីគ្លីនិកសុខភាពគ្រួសារ ដែលគាំទ្រដោយមន្ទីរសុខាភិបាលខេត្ត/កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍និងកាមរោគខេត្ត

៥.២.២ ចុះពិនិត្យតាមដាន និងអភិបាលសកម្មភាពរបស់គ្លីនិកសុខភាពគ្រួសារជាទៀងទាត់ រៀងរាល់ត្រីមាស ឬប្រាំមួយខែម្តង ប្រសិនបើចាំបាច់ ដើម្បីធានាបានថាគ្លីនិកសុខភាពគ្រួសាពិតជាបានផ្តល់សេវាថៃទាំព្យាបាលប្រកបដោយគុណភាពល្អ។

៥.២.៣ ទទួលបន្ទុកចំពោះការផ្គត់ផ្គង់ឱសថ សំភារៈ បរិក្ខារ និងការគ្រប់គ្រង (ការស្នើសុំ និងការបែងចែក)

៥.២.៤ សំរួល និងដោះស្រាយបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំសំរបសំរួលជាមួយភាគីដៃគូពាក់ព័ន្ធ។

៥.២.៥ សហការជាមួយស្ថាប័ននិងអង្គការជាដៃគូ ដើម្បីពង្រឹងសេវាថៃទាំព្យាបាល តាមរយៈការបង្កើនសមត្ថភាព ការធ្វើអោយគុណភាពនៃសេវាកាន់តែប្រសើរឡើង និងការធានាគុណភាពនៃការធ្វើតេស្ត

រកជំងឺកាមរោគនៅមន្ទីរពិសោធន៍ ព្រមទាំងការពង្រឹងទំនាក់ទំនងជាមួយសេវាផ្សេងៗទៀត ដូចជា សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ សេវាពន្យារកំណើត សេវាសុខភាពបន្តពូជ...។

៥.២.៦ រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ គំរោងថ៉ាន់ប្រមាណថវិកា និងគោលដៅនៃសកម្មភាពទាំងនោះ ដើម្បីដាក់ជូនមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ពិនិត្យនិងសំរេច និង ចែករំលែកពត៌មានទាំងនោះដល់អង្គការសុខភាពគ្រួសារអន្តរជាតិ។

៥.២.៧ បូកសរុបរបាយការណ៍ស្តីអំពីសកម្មភាពថែទាំព្យាបាលជំងឺកាមរោគ ជូនដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងចែករំលែកពត៌មានទាំងនោះដល់អង្គការសុខភាពគ្រួសារអន្តរជាតិ។

៥.២.៨ រៀបចំសំណើថវិកាសំរាប់ការអនុវត្តន៍សកម្មភាពប្រចាំត្រីមាស ដោយផ្អែកលើគំរោងចំណាយថវិការបស់អង្គការសុខភាពគ្រួសារអន្តរជាតិ។

## ៥.៣ ការទទួលខុសត្រូវរបស់អង្គការសុខភាពគ្រួសារអន្តរជាតិ

៥.៣.១ គាំទ្រដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងការរៀបចំវាយតំលៃតំរូវការរបស់គ្លីនិកសុខភាពគ្រួសារ ដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាពនៃសេវាថែទាំព្យាបាល។

៥.៣.២ ធ្វើការក្នុងភាពជាដៃគូជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មន្ទីរសុខាភិបាលខេត្ត/កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគខេត្ត និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត ដើម្បីធ្វើអោយ ការទៅទទួលសេវាថែទាំព្យាបាលជំងឺកាមរោគ សំរាប់ស្ត្រីបំរើសេវាកំសាន្តសប្បាយ និងក្រុមបុរសស្រឡាញ់បុរស មានភាពប្រសើរឡើងថែមទៀត។

៥.៣.៣ ផ្តល់ការគាំទ្រដល់ការបណ្តុះបណ្តាល, ការចុះទៅបង្ហាត់បង្ហាញផ្ទាល់នៅកន្លែងធ្វើការ និងជំនួយផ្នែកបច្ចេកទេសដែលទាក់ទងនឹងការពង្រឹងសកម្មភាពបង្ការ និងថែទាំព្យាបាលជំងឺកាមរោគ ជាពិសេសចំពោះក្រុមដែលប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់ ដូចជាស្ត្រីបំរើសេវាកំសាន្តសប្បាយ (នៅតាមផ្ទះបន និងក្រៅផ្ទះបន) និងក្រុមបុរសស្រឡាញ់បុរស។

៥.៣.៤ ផ្គត់ផ្គង់បរិក្ខារ សំភារៈការិយាល័យ និងឧបករណ៍ផ្សេងៗទៀត ដែលគ្លីនិកសុខភាពគ្រួសារត្រូវការជាចាំបាច់ ដើម្បីធានាបាននូវការផ្តល់សេវាថែទាំព្យាបាលដែលប្រកបដោយគុណភាពល្អ។

៥.៣.៥ សហការយ៉ាងជិតស្និទ្ធិជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មន្ទីរសុខាភិបាលខេត្ត/កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍និងកាមរោគខេត្ត, ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែក ដើម្បីពង្រឹងការគ្រប់គ្រងសេវាថែទាំព្យាបាលជំងឺកាមរោគដោយពឹងផ្អែកលើមន្ទីរពិសោធន៍ តាមរយៈការបង្កើនសមត្ថភាព, ការធ្វើអោយគុណភាពនៃសេវាកាន់តែ

ប្រសើរឡើង និងការធានាគុណភាពនៃការធ្វើតេស្តរកជំងឺកាមរោគនៅមន្ទីរពិសោធន៍ ព្រមទាំងការពង្រឹងទំនាក់ទំនងជាមួយសេវាបង្ការ និងថែទាំព្យាបាលជំងឺអេដស៍ផ្សេងៗទៀត និងសេវាសុខភាពបន្តពូជ...។

៥.៣.៦ ចូលរួមជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មន្ទីរសុខាភិបាលខេត្ត/កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍និងកាមរោគខេត្ត, ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដើម្បីធ្វើគំរោងផែនការសកម្មភាព និងដាក់បញ្ចូលគ្នាគំរោងផែនការនោះ ទៅក្នុងគំរោងប្រតិបត្តិនៃផែនការសកម្មភាពគ្រប់ជ្រុងជ្រោយប្រចាំឆ្នាំ។

៥.៣.៧ ធ្វើការដោយមានការពិគ្រោះយោបល់ និងសំរបសំរួលជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មន្ទីរសុខាភិបាលខេត្ត/កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍និងកាមរោគខេត្ត, ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ នៅក្នុងការរៀបចំផែនការសំរាប់កម្មវិធី, ការគ្រប់គ្រង, ការធ្វើអោយគុណភាពគុណភាពនៃសេវាកាន់តែប្រសើរឡើង និងការដោះស្រាយបញ្ហាផ្សេងៗ។

៥.៣.៨ ផ្តល់ការគាំទ្រជាប្រចាំ ដល់ការពង្រឹងសមត្ថភាពបច្ចេកទេស ជូនដល់មន្ត្រីផ្នែកគ្រប់គ្រងព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ និងមន្ត្រីនៃគ្លីនិកជាតិ សើស្បែក និងកាមរោគនៃមជ្ឈមណ្ឌលជាតិ ក្នុងការបង្ការ និងថែទាំព្យាបាលជំងឺកាមរោគ។

៥.៣.៩ ផ្តល់ការគាំទ្រដល់មធ្យោបាយធ្វើដំណើរសំរាប់ស្ត្រីបំរើសេវាកំសាន្តសប្បាយ ដើម្បីសំរួលដល់ស្ត្រីទាំងនោះអោយទៅទទួលសេវាថែទាំព្យាបាលនៅគ្លីនិកសុខភាពគ្រួសារ (ទោះបីយ៉ាងណាក៏ដោយ សេវាថែទាំព្យាបាលជំងឺកាមរោគបែបចល័ត ត្រូវអនុវត្តនៅទីកន្លែងណាដែលផ្ទះបននៅឆ្ងាយដាច់ស្រយាលពីគ្លីនិកសុខភាពគ្រួសារ ហើយការបញ្ជូន និងធ្វើដំណើររបស់ស្ត្រីទាំងនោះមកគ្លីនិក មិនអាចធ្វើទៅបាន)។

## ៦ ប្រភពនៃថវិកា

អង្គការសុខភាពគ្រួសារអន្តរជាតិ នឹងគាំទ្រផ្នែកបច្ចេកទេស និងថវិកាជូនដល់ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងមន្ទីរសុខាភិបាលខេត្ត តាមរយៈគំរោងប្រសិទ្ធ (PRASIT) ដើម្បីពង្រឹងគុណភាពនៃសេវាថែទាំព្យាបាលជំងឺកាមរោគសំរាប់ក្រុមប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់។ សកម្មភាពទាំងនេះ នឹងត្រូវបានអនុវត្តនៅតាមគ្លីនិកសុខភាពគ្រួសារទាំង ១៣ នៃខេត្តចំនួន ៩ ក្នុងគំរោងថវិកាសរុបចំនួន ២២,៣០០ ដុល្លារអាមេរិក សំរាប់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង ១៨,០០០ ដុល្លារអាមេរិក សំរាប់គ្លីនិកសុខភាពគ្រួសារនៅតាមខេត្តដែលបានចុះកិច្ចព្រមព្រៀងសំរាប់ឆ្នាំសារពើពន្ធ ដែលគិតពី ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែកញ្ញា ឆ្នាំ២០០៩ ។

## ៧ ការព្រមព្រៀងជាទូទៅ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការសុខភាពគ្រួសារអន្តរជាតិ បានយល់ព្រមចំពោះគំរោងបែងចែកកញ្ចប់ថវិកាសំរាប់សកម្មភាពថែទាំព្យាបាលជំងឺកាមរោគនេះ ។ ការផ្លាស់ប្តូរ ឬ ការកែប្រែណាមួយក្នុងកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបាន លុះត្រាតែភាគីទាំងពីរបានធ្វើការពិគ្រោះយោបល់ និង ឯកភាពគ្នា ។

ការផ្តល់ថវិកាសំរាប់ចំណាយក្នុងការអនុវត្តន៍សកម្មភាពនានា ត្រូវបានធ្វើឡើងដោយសមស្របទៅតាមគំរោងផែនការថវិកាប្រចាំត្រីមាស និងការចំណាយពិតប្រាកដ តាមរយៈរបាយការណ៍នៃការចំណាយថវិកាប្រចាំត្រីមាសនិមួយៗ ។

និតិវិធីទូទៅ, ការសំរបសំរួល, ការរៀបចំគំរោងផែនការ និងការគ្រប់គ្រងសកម្មភាពខាងលើនេះ ត្រូវបានអនុវត្តរួមគ្នាដោយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មន្ទីរសុខាភិបាលខេត្ត/កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍និងកាមរោគខេត្ត និងអង្គការសុខភាពគ្រួសារអន្តរជាតិប្រចាំប្រទេសកម្ពុជា សមស្របទៅតាមគំរោងផែនការរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគនៃក្រសួងសុខាភិបាល "*ផែនការយុទ្ធសាស្ត្រសំរាប់ការបង្ការ និងថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ឆ្នាំ២០០៨-២០១០*" និងតាម *និយាមនៃបែបបទសំរាប់អនុវត្តសកម្មភាព* របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៧ ។

| | |
|---|---|
| ថ្ងៃទី...០៩.....ខែ.....មករា.....ឆ្នាំ ២០០៩ | ថ្ងៃទី....០៩....ខែ.....មករា.....ឆ្នាំ ២០០៩ |
| **ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ** | **ប្រធានអង្គការសុខភាពគ្រួសារអន្តរជាតិ ប្រចាំប្រទេសកម្ពុជា** |
| **វេជ្ជ. មាន ឈីវុន** | **វេជ្ជ. Peter Cowley** |